**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## បាឋកថាអាស៊ានលើកទី២៣ ស្តីពី
## ព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាប្រធានអាស៊ាន ឆ្នាំ២០២២
**០៣ មករា ២០២២**

នៅថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២២ តបតាមការអញ្ជើញរបស់វិទ្យាស្ថាន ISEAS - Yusof Ishak **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញផ្តល់ «បាឋកថាអាស៊ានលើកទី២៣៖ កម្ពុជាក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២» តាមប្រព័ន្ធវីដេអូ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរដល់វិទ្យាស្ថាន ISEAS - Yusof Ishak ចំពោះទម្លាប់នៃការអនុវត្តរបស់ខ្លួនក្នុងការរៀបចំបាឋកថាជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីអាស៊ាន និងកិច្ចខិតខំប្រឹងប្រែងនានាឆ្ពោះទៅការកសាងសហគមន៍អាស៊ាន ដែលផ្តោតទៅលើប្រជាជន និងយកប្រជាជនជាស្នូល។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានពន្យល់យ៉ាងលម្អិតអំពីចង្កោមចំនួនបួន នៃបញ្ហាប្រឈមជាយុទ្ធសាស្ត្ររួមមាន ការស្តារឡើងវិញក្រោយពីផលប៉ះពាល់នៃជំងឺកូវីដ-១៩ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ បញ្ហាប្រឈមផ្នែកសន្តិសុខទាំងជាប្រពៃណី និងមិនមែនជាប្រពៃណីដែលមានស្រាប់ និងបញ្ហាប្រឈមផ្ទៃក្នុង និងនៅក្នុងស្ថាប័នរបស់អាស៊ាន ដែលបញ្ហាប្រឈមទាំងនេះ នាំឱ្យកម្ពុជា ជ្រើសរើសការដឹកនាំដំណើរការអាស៊ាននៅឆ្នាំ ២០២២ របស់ខ្លួន ក្រោមមូលបទ «អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា»។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់អំពីសារសំខាន់នៃស្មារតីរបស់អាស៊ាន ក្នុងនាមជាគ្រួសាររួបរួមគ្នាមួយដែលមានសមាជិកចំនួន១០ប្រទេស ក្នុងការជម្នះបញ្ហាប្រឈមរួម និងស្មារតីដ៏រឹងមាំនៃ «ទាំងអស់រួមគ្នា» ដើម្បីលើកកម្ពស់ប្រកបដោយប្រសិទ្ធភាពនូវសន្តិភាព ស្ថិរភាព និងបន្តជំរុញបន្ថែមទៀតនូវការអភិវឌ្ឍប្រកបដោយចីរភាព ទាំងនៅក្នុង និងក្រៅតំបន់។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងអំពីអាទិភាព សមិទ្ធផល និងទស្សនវិស័យសំខាន់ៗនានារបស់កម្ពុជា នៅក្នុងសហគមន៍អាស៊ានទាំងបី រួមមានសហគមន៍សន្តិសុខ-នយោបាយអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមក្នុងតំបន់។ (សូមជូនភ្ជាប់មកជាមួយនូវអត្ថបទទាំងស្រុងនៃបទអន្តរាគមន៍)

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 21[illegible]
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានទទួលឆ្លើយសំណួរពីអ្នកចូលរួម អំពីបញ្ហាតំបន់និងអន្តរជាតិ ពាក់ព័ន្ធនឹងផលប្រយោជន៍ និងកង្វល់របស់អាស៊ាន ក្នុងអំឡុងពេលនៃការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា នៅឆ្នាំ២០២២៕

ថ្ងៃចន្ទ ១ កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០២២